ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

<u>នាយកដ្ឋានព័ត៌មាន</u>

# សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលកិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា-វៀតណាម លើកទី១៧
## ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
## ថ្ងៃទី២០-២១ ខែសីហា ឆ្នាំ២០១៩ នៅរាជធានីភ្នំពេញ

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើជាសហប្រធានជាមួយឯកឧត្តម **ផាម ប៊ិញមិញ** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដឹកនាំកិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា-វៀតណាមលើកទី១៧ (17th JC) ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា នៅថ្ងៃទី ២១ ខែសីហាឆ្នាំ ២០១៩ នៅរាជធានីភ្នំពេញ។ មុនពេលអញ្ជើញចូលរួមកិច្ចប្រជុំ **ឯកឧត្តម ផាម ប៊ិញ មិញ** បានចូលជួបសម្តែងការគួរសមជាមួយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

នៅអំឡុងកិច្ចប្រជុំគណៈកម្មការចម្រុះលើកទី១៧នេះ ភាគីទាំងពីរបានគូសបញ្ជាក់អំពីសារៈសំខាន់ និងលទ្ធផលជាវិជ្ជមាននៃការផ្លាស់ប្តូរទស្សនកិច្ចរបស់ថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់នៃបណ្តាក្រសួង ស្ថាប័ន និង ខេត្តនានា។ ភាគីទាំងពីរ ក៏បានទទួលស្គាល់ផងដែរនូវកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសទាំងពីរក្នុងការសម្របសម្រួលជំហរផ្សេងៗនៅក្នុងវេទិកាពហុភាគី ជាពិសេសនៅក្នុងតំបន់អាស៊ាន ព្រមទាំងបានអះអាងជាថ្មីនូវការប្តេជ្ញាបន្តកិច្ចសហការយ៉ាងជិតស្និទ្ធនៅក្នុងក្របខ័ណ្ឌទាំងនេះ ដើម្បីបម្រើផលប្រយោជន៍រួម និងរួមចំណែកដល់សន្តិភាព ស្ថិរភាព និង វិបុលភាពនៅក្នុងតំបន់ និងពិភពលោក។

ភាគីទាំងពីរបានកត់សម្គាល់ដោយពេញចិត្ត ចំពោះវឌ្ឍនភាពដ៏ល្អនៃកិច្ចសហប្រតិបត្តិការទ្វេភាគីនៅក្នុងវិស័យផ្សេងៗ ទាំងផ្នែកវិសាលភាព និងប្រសិទ្ធភាព និងបានឯកភាពពង្រីកនិងពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការទាំងនោះ។

សម្រាប់កិច្ចសហប្រតិបត្តិការលើវិស័យអប់រំ និងការអភិវឌ្ឍធនធានមនុស្ស ភាគីទាំងពីរបានឯកភាពបន្តអនុវត្តប្រកបដោយប្រសិទ្ធភាពនូវ "អនុស្សរណៈនៃកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការអប់រំ សម្រាប់ឆ្នាំ២០១៦-២០២០" ដែលបានចុះហត្ថលេខានៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៦ និងផែនការសហប្រតិបត្តិការអប់រំ សម្រាប់ឆ្នាំ ២០១៩ ដែលបានចុះហត្ថលេខានៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ ។



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141; 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

នៅក្នុងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ភាគីទាំងពីរបានឯកភាពជំរុញកិច្ចសហប្រតិបត្តិការអនាម័យនិងភូតគាមអនាម័យ ដើម្បីទប់ស្កាត់ការរាតត្បាតនៃសត្វល្អិតចង្រៃនិងជំងឺឆ្លង នៅតាមតំបន់ព្រំដែនរវាងប្រទេសកម្ពុជានិងវៀតណាម។ ភាគីទាំងពីរបានបញ្ជាក់ជាថ្មីនូវកិច្ចខិតខំប្រឹងប្រែងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការទប់ស្កាត់ ប្រយុទ្ធប្រឆាំង និងបង្ក្រាបរាល់ការធ្វើពាណិជ្ជកម្មឆ្លងកាត់ព្រំដែនដោយខុសច្បាប់។ ភាគីទាំងពីរក៏បានយល់ព្រមជំរុញកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍដំណាំហូបផ្លែ និងដំណាំឧស្សាហកម្មផងដែរ។

សម្រាប់វិស័យថាមពល ភាគីទាំងពីរបានឯកភាពពង្រឹងថែមទៀតនូវកិច្ចសហប្រតិបត្តិការលើពាណិជ្ជកម្មអគ្គិសនី និងការអភិវឌ្ឍបណ្តាញចែកចាយថាមពល។

ចំពោះកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម វិនិយោគ និងឧស្សាហកម្មវិញ ភាគីទាំងពីរបានឯកភាពថាទំហំពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរ អាចនឹងសម្រេចបានចំនួន**៥ប៊ីលានលានដុល្លារអាមេរិក**នៅឆ្នាំ២០២០ ហើយដែលអាចកើនលើសគោលដៅដែលបានរំពឹងទុក។ ភាគីទាំងពីរក៏បានវាយតម្លៃខ្ពស់ផងដែរចំពោះកិច្ចខិតខំប្រឹងប្រែងសម្របសម្រួល ដើម្បីជំរុញការវិនិយោគទ្វេភាគី ដោយស្របទៅតាមច្បាប់ស្តីពីការវិនិយោគនិងច្បាប់ពាក់ព័ន្ធដទៃទៀតរបស់ប្រទេសទាំងសងខាង និងពន្លឿនការបញ្ចប់កិច្ចព្រមព្រៀងពាណិជ្ជកម្មតាមព្រំដែន ដែលបច្ចុប្បន្ននេះ កំពុងស្ថិតនៅក្នុងការពិភាក្សានៅឡើយ។ ភាគីទាំងពីរបានឯកភាពធ្វើឱ្យដំណើរការឡើងនូវកិច្ចសហប្រតិបត្តិការក្នុងឧស្សាហកម្មតម្លៃបន្ថែមខ្ពស់មានដូចជា វេជ្ជសាស្ត្រ ផលិតផលអគ្គិសនី និងគ្រឿងអេឡិចត្រូនិច យានយន្ត និងបានឯកភាពជំរុញការវិនិយោគកសិ-ឧស្សាហកម្មនៅតាមព្រំដែននៃប្រទេសទាំងពីរ។

សម្រាប់កិច្ចសហប្រតិបត្តិការលើវិស័យអាកាសចរណ៍ស៊ីវិល ភាគីទាំងពីរបានឯកភាពបន្តគាំទ្រ និងបង្កើតនូវលក្ខខណ្ឌអំណោយផលសម្រាប់ក្រុមហ៊ុនអាកាសចរណ៍កម្ពុជាអង្គរអ៊ែរ ក្នុងឋានៈជាក្រុមហ៊ុនអាកាសចរណ៍ជាតិរបស់កម្ពុជា ដើម្បីធ្វើប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពនិងអភិវឌ្ឍប្រកបដោយចីរភាព។

ចំពោះវិស័យទេសចរណ៍ ភាគីទាំងពីរបានឯកភាពពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀតក្នុងការអភិវឌ្ឍទេសចរណ៍ តាមរយៈការពន្លឿនសកម្មភាពផ្សព្វផ្សាយនិងទីផ្សាររួមគ្នា និងបានឯកភាពបង្កើនការតភ្ជាប់ក្នុងចំណោមគោលដៅទេសចរណ៍ និងផលិតផលនៃប្រទេសទាំងពីរ។

ចំពោះបញ្ហាព្រំដែន ភាគីទាំងពីរបានកត់សម្គាល់ដោយពេញចិត្ត ចំពោះលទ្ធផលជាវិជ្ជមានក្នុងការកំណត់ខ័ណ្ឌសីមា និងការបោះបង្គោលព្រំដែន ដែលភាគីទាំងពីរសម្រេចបាន បន្ទាប់ពីកិច្ចប្រជុំគណៈកម្មការចម្រុះកម្ពុជា-វៀតណាមលើកទី១៦ កាលពីខែឧសភា ឆ្នាំ២០១៨ នៅទីក្រុងហាណូយ។ ភាគីទាំងពីរបានស្វាគមន៍កំណត់ហេតុរបស់ប្រធានគណៈកម្មការចម្រុះខ័ណ្ឌសីមា និងការបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម (Joint Commission on Demarcation and Abornement for Land Boundary-JBC) ដែលបានចុះហត្ថលេខា នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ នៅរាជធានីភ្នំពេញ ដែលនៅពេលនោះ ភាគីទាំងពីរបានឯកភាពលើលិខិតុបករណ៍ច្បាប់ចំនួនពីរ ដើម្បីទទួលស្គាល់ការបញ្ចប់ការកំណត់ខ័ណ្ឌសីមាព្រំដែនគោក និងការបោះបង្គោលព្រំដែន បានចំនួន៨៤% និងបាន

ឯកភាពទៅលើទំហំការងារ ផែនការសម្របសម្រួល និងផែនទីចង្អុលផ្លូវក្នុងការអនុវត្ត រហូតដល់ឯកសារផ្លូវច្បាប់ទាំងពីរនេះត្រូវបានចុះហត្ថលេខា។

សម្រាប់កិច្ចសហប្រតិបត្តិការលើវិស័យសន្តិសុខ និងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្ម ភាគីទាំងពីរបានឯកភាពពង្រឹងកិច្ចសហប្រតិបត្តិការ និងការគាំទ្រគ្នាទៅវិញទៅមក នៅក្នុងវេទិកាតំបន់ និងអន្តរជាតិ ដូចជា INTERPOL និង ASEANAPOL និងបានឯកភាពធ្វើការរួមគ្នាក្នុងការដោះស្រាយបញ្ហាសន្តិសុខមិនមែនប្រពៃណី។

ក្រៅពីចំណុចដែលបានលើកឡើងខាងលើ ភាគីទាំងពីរបានឯកភាពបង្កើនល្បឿនការអនុវត្តសកម្មភាព និងគម្រោងពាក់ព័ន្ធផ្សេងទៀត ដែលមានការយឺតយ៉ាវក្នុងការអនុវត្ត ក្នុងខណៈពេលកំពុងរិះរកវិធានការថ្មី និងប្រាកដប្រជា ដើម្បីកែលំអកិច្ចសហប្រតិបត្តិការថែមទៀត និងសម្រេចឲ្យបានលទ្ធផលជាអតិបរមា ដើម្បីជាប្រយោជន៍រួមរបស់ប្រទេសទាំងពីរ ។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន និង ឯកឧត្តម ផាម ប៊ិញ មិញ** បានឯកភាពរៀបចំកិច្ចប្រជុំគណៈកម្មការចម្រុះលើកទី១៨ នៅប្រទេសវៀតណាម នាឆ្នាំក្រោយ ហើយនៅចុងបញ្ចប់នៃការពិភាក្សា រដ្ឋមន្ត្រីការបរទេសទាំងពីរបានចុះហត្ថលេខាលើកំណត់ហេតុស្តីពីលទ្ធផលនៃកិច្ចប្រជុំគណៈកម្មការចម្រុះលើកទី១៧ ៕

ថ្ងៃ សុក្រ ៨រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១៩